ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការធ្វើអនុបយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជ្យក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ១៣៧/១៩ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តព្រះវិហារ

## សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដី១កន្លែងទំហំ ២០ ០០០(ម្ភៃពាន់) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិភារកិច្ច សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដូចបង្ហាញក្នុងផែនទីដែលមាននិយាមការភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ផ្ទៃដីដែលបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់ចែងនីតិវិធីបន្តដោយក្រសួងសាធារណការនិងដឹកជញ្ជូន ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការស្របតាមនីតិវិធីប្រទានកម្មជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣ រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែតុលា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ប្លង់ឧបសម្ព័ន្ធភ្ជាប់ជាមួយកំណត់ហេតុប្រជុំដោះស្រាយបញ្ចប់ទំនាស់ដីធ្លី(ដីសម្បទានសាធារណការ និងដីអាជ្ញាធរខេត្ត)
ស្ថិតក្នុងភូមិតាអកិច្ច សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ




បញ្ជីឈ្មោះប្រជាពលរដ្ឋចំនួន ០៦ គ្រួសារ

១=លោក នួន សុរិរិទ្ធ និងនាង ប៊ុន ស៊ីវហុង ទំហំ ៩១៥៥.៦២ ម៉ែត្រការ៉េ
២=លោក ខេត វ៉ាន់ឌី និងលោក ឆាយ ហេង ទំហំ ៦៦៧៤.៩០ ម៉ែត្រការ៉េ
៣=លោក ញុប វណ្ណី និងនាង ពៅ សុគន្ធា ទំហំ ១២២៧ ម៉ែត្រការ៉េ
៤=លោក ឆយ បូរ៉ា និងនាង រស់ ស៊ីម៉ុន ទំហំ ១៤៤០ ម៉ែត្រការ៉េ
៥=លោក យូ ជីវិន ទំហំ ៣៩២០.០៩ ម៉ែត្រការ៉េ
៦=លោក គាន់ គង់អ៊ី និងនាង ងួន បូណា ទំហំ ១៩៨២.៣៩ ម៉ែត្រការ៉េ

| ID | UTM_X | UTM_Y | ID | UTM_X | UTM_Y | ID | UTM_X | UTM_Y |
|---|---|---|---|---|---|---|---|---|
| 1 | 497448 | 1524225 | 10 | 497333 | 1524151 | 19 | 497222 | 1524146 |
| 2 | 497441 | 1524225 | 11 | 497323 | 1524152 | 20 | 497225 | 1524154 |
| 3 | 497404 | 1524229 | 12 | 497319 | 1524153 | 21 | 497237 | 1524200 |
| 4 | 497289 | 1524239 | 13 | 497310 | 1524153 | 22 | 497237 | 1524200 |
| 5 | 497290 | 1524213 | 14 | 497309 | 1524160 | 23 | 497239 | 1524201 |
| 6 | 497303 | 1524216 | 15 | 497422 | 1524128 | 24 | 497252 | 1524203 |
| 7 | 497304 | 1524205 | 16 | 497410 | 1524129 | 25 | 497248 | 1524243 |
| 8 | 497438 | 1524190 | 17 | 497325 | 1524137 | 26 | 497249 | 1524243 |
| 9 | 497423 | 1524137 | 18 | 497321 | 1524137 | | | |

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២០
ប្រធានបើកការ និងឯកភាព
អភិបាលក្រុងព្រះវិហារ ស្តីទី
ប៊ុក_ខួន

ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០២០
វាស់វែង និងគូរដោយមន្ត្រីជំនាញការិយាល័យ ដ.ន.ស.ភ ក្រុងព្រះវិហារ
សាន ប្រុស